**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការ
ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
លេខ: ០២/១៥ គ.ទ.ក. ស.ស.ស

# សេចក្តីសម្រេច
# ស្តីពី
# គោលការណ៍ជ្រើសរើសមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា

## ប្រធាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦១ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៧១ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា១០ថ្មី មាត្រា១៤ថ្មី មាត្រា១៥ថ្មី និងមាត្រា១៦ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ មាត្រា១៣ថ្មី មាត្រា៣០ថ្មី និងមាត្រា១១ថ្មីស្ទួន នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ និងមាត្រា៦១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា



moeys.gov.kh | fb.com/moeys.gov.kh | google.com/+moeys | twitter.com/moeyscambodia

ទីស្តីការគណៈរដ្ឋមន្ត្រី, អគារមិត្តភាពលេខ៤១, ជាន់ទី៤ មហាវិថី សហព័ន្ធរុស្ស៊ី, រាជធានីភ្នំពេញ, គេហទំព័រ: www.acc.gov.kh, អ៊ីមែល: info@acc.gov.kh, ទូរស័ព្ទ: (855)23 224 620, (855)12 719 887, (855)17 338 896

- បានឃើញសេចក្តីសម្រេចលេខ ០១/១៥ គ.ទ.ក សសរ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ របស់ គ.ទ.ក. ស្តីពី ការដាក់ឱ្យប្រើប្រាស់ស្តង់ដាជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា
- យោងតាមសំណើរបស់អគ្គលេខាធិការនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

សេចក្តីសម្រេចនេះមានគោលដៅកំណត់ អំពីគោលការណ៍ជ្រើសរើសមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាដើម្បីចូលរួមក្នុងដំណើរការវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា(គ.ទ.ក.)។

## ជំពូកទី ២

## លក្ខខណ្ឌ និង ដំណើរការជ្រើសរើស

**ប្រការ២.-**

បេក្ខជនទាំងពីរភេទដែលមានសញ្ជាតិខ្មែរ ឬ ជាជនបរទេស ត្រូវមានលក្ខណៈសម្បត្តិ ដូចខាងក្រោម ៖

- មានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅដែលទទួលបានពីគ្រឹះស្ថានឧត្តមសិក្សាដែលមានការទទួលស្គាល់គុណភាពអប់រំ ឬ ទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ច
- មានបទពិសោធន៍ការងារយ៉ាងតិច១០ឆ្នាំ ក្នុងការបង្រៀននៅឧត្តមសិក្សា កិច្ចការសិក្សាធិការ ការធានាគុណភាពអប់រំ ការទទួលស្គាល់គុណភាពអប់រំ ការរៀបចំគោលនយោបាយ ឬ/និង ការគ្រប់គ្រងស្ថាប័ន
- មានបទពិសោធន៍ក្នុងការស្រាវជ្រាវ រួមមាន ការសរសេរនិក្ខេបបទ ការត្រួតពិនិត្យនិងវាយតម្លៃគម្រោងផ្សេងៗ ស្នាដៃស្រាវជ្រាវដែលបោះពុម្ពផ្សាយមានការទទួលស្គាល់ជាលក្ខណៈជាតិ ឬ អន្តរជាតិ
- មានសីលធម៌ល្អ ការទទួលខុសត្រូវខ្ពស់លើការងារ ការប្តេជ្ញាចិត្ត ជំនាញអន្តរបុគ្គល ជំនាញទំនាក់ទំនង និង អាចធ្វើការជាក្រុម
- ចំពោះបេក្ខជនទាំងពីរភេទដែលជាជនបរទេស ត្រូវមានទិដ្ឋាការស្នាក់នៅកម្ពុជាដែលអាចបំរើការងារជាមន្ត្រីវាយតម្លៃយ៉ាងតិចមួយឆ្នាំក្នុងអាណត្តិរបស់ខ្លួន
- ចេះភាសាអង់គ្លេសកម្រិតមធ្យម និង ជំនាញកុំព្យូទ័រ Word Processing or/and SPSS ។

**ប្រការ៣.-**

ដំណើរការជ្រើសរើសមន្ត្រីវាយតម្លៃត្រូវអនុវត្តដូចខាងក្រោម៖



moeys.gov.kh | fb.com/moeys.gov.kh | google.com/+moeys | twitter.com/moeyscambodia

- អគ្គលេខាធិការដ្ឋាន គ.ទ.ក. រៀបចំដំណើរការជ្រើសរើស បណ្តុះបណ្តាល និង លើកសំណើតែងតាំងជាមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាជូនប្រធាន គ.ទ.ក. ពិនិត្យនិងសម្រេច
- អគ្គលេខាធិការដ្ឋាន គ.ទ.ក. បង្កើតគណៈកម្មការជ្រើសរើសមួយដែលមានសមាសភាព និងភារកិច្ចដូចមានចែងក្នុងប្រការ៤ នៃសេចក្តីសម្រេចនេះ។

**ប្រការ៤.-**

គណៈកម្មការជ្រើសរើសមានពី ៥(ប្រាំ)រូប ទៅ ៩(ប្រាំបួន)រូប រួមមាន សមាសភាពមកពីអគ្គលេខាធិការដ្ឋាន គ.ទ.ក. និង/ឬ តំណាងដៃគូអភិវឌ្ឍន៍ ។ គណៈកម្មការនេះ មានអគ្គលេខាធិការ គ.ទ.ក. ជាប្រធាន ។

គណៈកម្មការជ្រើសរើសមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំកម្រងសំណួរដើម្បីសម្ភាសបេក្ខជនមន្ត្រីវាយតម្លៃ
- ពិនិត្យ និង វាយតម្លៃសំណុំឯកសាររបស់បេក្ខជនមន្ត្រីវាយតម្លៃ
- រៀបចំដំណើរការសម្ភាសបេក្ខជនមន្ត្រីវាយតម្លៃ
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការសម្ភាសជ្រើសរើសបេក្ខជនមន្ត្រីវាយតម្លៃ ជូន គ.ទ.ក.។

គណៈកម្មការជ្រើសរើស ប្រើប្រាស់ទម្រង់លិខិតនិងត្រារបស់អគ្គលេខាធិការដ្ឋាន គ.ទ.ក. និង មានសិទ្ធិ ប្រើប្រាស់មន្ត្រីរបស់អគ្គលេខាធិការដ្ឋាន គ.ទ.ក. ជាជំនួយការ។

## ជំពូកទី ៣

## អាណត្តិ និង ប្រាក់ឧបត្ថម្ភ

**ប្រការ៥.-**

អាណត្តិរបស់មន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាមានរយៈពេល៣(បី)ឆ្នាំ ហើយអាចត្រូវបានតែងតាំងឡើងវិញសម្រាប់អាណត្តិបន្ទាប់ដោយ គ.ទ.ក. តាមសំណើរបស់អគ្គលេខាធិការ ។ មន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា ត្រូវបានជ្រើសរើសឱ្យបម្រើការងារទៅតាមតម្រូវការនៃការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា។

**ប្រការ៦.-**

មន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា ទទួលប្រាក់ឧបត្ថម្ភការងារតាមការកំណត់របស់ គ.ទ.ក. នៅពេលចុះវាយតម្លៃគុណភាពអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

**ប្រការ៧.-**

មន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាអាចត្រូវបានបញ្ឈប់មុនអាណត្តិ ក្នុងករណីណាមួយដូចខាងក្រោម៖

- សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរ
- សាមីខ្លួនត្រូវបានរកឃើញថាមានលក្ខណៈណាមួយដែលផ្ទុយនឹងប្រការ២នៃសេចក្តីសម្រេចនេះ
- សាមីខ្លួនត្រូវបានតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ
- សាមីខ្លួនពុំបានផ្តល់របាយការណ៍ទាន់ពេលវេលាតាមការកំណត់របស់ គ.ទ.ក. រយៈពេល៣ដង



moeys.gov.kh | fb.com/moeys.gov.kh | google.com/+moeys | twitter.com/moeyscambodia

- សាមីខ្លួនប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌របស់អ្នកវាយតម្លៃគុណភាពអប់រំ ដែលកំណត់ដោយ គ.ទ.ក.។

## ជំពូកទី ៤
## បទប្បញ្ញត្តិដោយឡែក

**ប្រការ៨.-**

គណៈកម្មការជ្រើសរើស អាចជ្រើសរើសបេក្ខជនមន្ត្រីវាយតម្លៃក្នុងចំណោមមន្ត្រីមកពីសមាជិកនៃភ្នាក់ងារបណ្ដាញគុណភាពអប់រំអាស៊ីប៉ាស៊ីហ្វិច(APQN) ឬបណ្ដាញជានាគុណភាពអាស៊ាន(AQAN) ឬសមាជិកនៃបណ្ដាញសាកលវិទ្យាល័យអាស៊ាន(AUN) ឬ មកពីអង្គការ SEAMEO RIHED ឬមកពីស្ថាប័នទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សានៃប្រទេសនានា ដើម្បីដាក់ជូន គ.ទ.ក. ពិនិត្យនិងសម្រេចតែងតាំងជាមន្ត្រីវាយតម្លៃ។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**ប្រការ៩.-**

សមាជិកគណៈកម្មការជ្រើសរើសដែលជាមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ទ.ក. ហើយមានលក្ខណៈសម្បត្តិដូច កំណត់ក្នុងប្រការ២ត្រូវបានតែងតាំងជាមន្ត្រីវាយតម្លៃរបស់ គ.ទ.ក. តាមសំណើរបស់ប្រធានគណៈកម្មការជ្រើសរើស។ គោលការណ៍នេះអនុវត្តតែក្នុងដំណាក់កាលដំបូងប៉ុណ្ណោះ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ១០.-**

សេចក្ដីសម្រេចលេខ០១/០៥ គ.ទ.ក. សសរ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៥ ស្ដីពីការជ្រើសរើសមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាត្រូវទុកជានិរាករណ៍ និង ជំនួសដោយសេចក្ដីសម្រេចនេះ។

**ប្រការ១១.-**

សមាជិកគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា អគ្គលេខាធិការនៃគ.ទ.ក. អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋាននិងប្រធាននាយកដ្ឋាន ចំណុះក្រសួងអប់រំ យុវជន និងកីឡា គណៈគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង ភាគីពាក់ព័ន្ធ ត្រូវអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៥

**ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**កន្លែងទទួល:**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់សមាជិក គ.ទ.ក.
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- គ្រប់គ្រឹះស្ថានឧត្តមសិក្សា
- ដូចប្រការ១១
- ឯកសារ-កាលប្បវត្តិ



moeys.gov.kh | fb.com/moeys.gov.kh | google.com/+moeys | twitter.com/moeyscambodia